**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់លក្ខណៈសម្បត្តិ និងឋានៈគ្រូនគរបាលជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

-បានឃើញ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាលទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា

-យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានកំណត់លក្ខណៈសម្បត្តិនិងឋានៈគ្រូនគរបាលជាតិ ។ ការកំណត់នេះក្នុងគោលបំណងលើកកំពស់គុណភាពគ្រូនគរបាលជាតិ សំដៅបង្កើនប្រសិទ្ធភាពការងារបណ្តុះបណ្តាល និង ការអភិវឌ្ឍធនធានមនុស្សក្នុងជួរមន្ត្រីនគរបាលជាតិ ឱ្យបានសមស្របទៅនឹងការរីកចម្រើនរបស់ប្រទេសជាតិ ។ គ្រូនគរបាលជាតិត្រូវស្ថិតក្រោមការគ្រប់គ្រងពីបណ្ឌិត្យសភានគរបាលកម្ពុជា ។

**មាត្រា២ :** គ្រូនគរបាលជាតិមានតួនាទី ភារកិច្ច សិក្សាស្រាវជ្រាវ អប់រំ និងបណ្តុះបណ្តាល ជូនដល់សិស្ស និស្សិត កម្មសិក្សាការី និងនគរបាលជាតិគ្រប់លំដាប់ថ្នាក់ ។

**មាត្រា៣ :** គ្រូនគរបាលជាតិត្រូវបានបែងចែកជា ៣ កម្រិត :

១. គ្រូនគរបាលជាតិ កម្រិតឧត្តម

២. គ្រូនគរបាលជាតិ កម្រិតមធ្យម

៣. គ្រូនគរបាលជាតិ កម្រិតបឋម

**មាត្រា៤ :** គ្រូនគរបាលជាតិត្រូវបានជ្រើសរើសក្នុងចំណោម មន្ត្រីនគរបាលជាតិទាំងពីរភេទ តាមរយៈការប្រឡងប្រជែង និង គ្រូនគរបាលជាតិទាំងពីរភេទ ដែលបានបង្ហាត់បង្រៀនកន្លងមក តាមរយៈការវាយតម្លៃរបស់ក្រសួងមហាផ្ទៃ ដោយផ្អែកលើលក្ខណៈសម្បត្តិរបស់គ្រូនគរបាលជាតិ ដែលមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ។

**មាត្រា៥ :** គ្រូនគរបាលជាតិជ្រើសរើសថ្មី ត្រូវទទួលការបណ្តុះបណ្តាលគរុកោសល្យ និងធ្វើកម្មសិក្សារយៈពេល៦ខែ ទើបធ្វើការតាំងស៊ប់ ជាគ្រូនគរបាលជាតិពេញសិទ្ធិ ។

**មាត្រា៦ :** លក្ខណៈសម្បត្តិគ្រូនគរបាលជាតិត្រូវបានកំណត់ដូចខាងក្រោម :

ក.គ្រូនគរបាលជាតិ កម្រិតឧត្តម

- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រសមមូលឡើងទៅ
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច៣ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬ ក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ និងកាយសម្បទាមាំមួន

ខ.គ្រូនគរបាលជាតិ កម្រិតមធ្យម

- មានសញ្ញាបត្របរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច២ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ កាយសម្បទាមាំមួន

គ.គ្រូនគរបាលជាតិ កម្រិតបឋម

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រសមមូល
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច១ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬ ក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ កាយសម្បទាមាំមួន

**មាត្រា៧ :** ត្រូវបានចាត់ថ្នាក់គ្រូនគរបាលជាតិ ដូចខាងក្រោម :

- គ្រូនគរបាលជាតិ កម្រិតឧត្តម មាន ៤ ថ្នាក់
- គ្រូនគរបាលជាតិ កម្រិតមធ្យម មាន ៤ ថ្នាក់
- គ្រូនគរបាលជាតិ កម្រិតបឋម មាន ៤ ថ្នាក់

**មាត្រា៨** : ការតម្លើងថ្នាក់គ្រូនគរបាលជាតិ ត្រូវធ្វើឡើងទៅតាមវេនជ្រើសរើស ។ ប៉ុន្តែមិនអាចអនុវត្តបានប្រសិនបើគ្រូនគរបាលជាតិណាបម្រើការងារមិនគ្រប់តាមលក្ខខណ្ឌ និង រយៈពេលកំណត់។ រយៈពេលដែលត្រូវតម្លើងថ្នាក់មានដូចខាងក្រោម :

ក.គ្រូនគរបាលជាតិ កម្រិតឧត្តម មាន ៤ ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៦ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៥ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៥ ឆ្នាំ |

ខ.គ្រូនគរបាលជាតិ កម្រិតមធ្យម មាន ៤ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៥ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៤ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៤ ឆ្នាំ |

គ.គ្រូនគរបាលជាតិ កម្រិតបឋម មាន ៤ ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៤ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៣ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៣ ឆ្នាំ |

**មាត្រា៩** : ត្រូវបានកំណត់ឋានៈមូលដ្ឋានសំរាប់គ្រូនគរបាលជាតិ ដូចខាងក្រោម :

ក. គ្រូនគរបាលជាតិ កំរិតឧត្តម

- ថ្នាក់លេខ១ : មានឋានៈស្មើ អគ្គនាយករង
- ថ្នាក់លេខ២ : មានឋានៈស្មើ ប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយការិយាល័យ ចំណុះនាយកដ្ឋាន

ខ. គ្រូនគរបាលជាតិ កំរិតមធ្យម

- ថ្នាក់លេខ១ : មានឋានៈស្មើ ប្រធាននាយកដ្ឋាន
- ថ្នាក់លេខ២ : មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ នាយការិយាល័យចំណុះនាយកដ្ឋាន

- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយរងការិយាល័យចំណុះនាយកដ្ឋាន

គ.គ្រូនគរបាលជាតិ កំរិតបឋម

- ថ្នាក់លេខ១ : មានឋានៈស្មើ នាយការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ២ : មានឋានៈស្មើ នាយរងការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ នាយផ្នែកនៃការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយរងផ្នែកនៃការិយាល័យចំណុះនាយកដ្ឋាន

**មាត្រា១០** : ការតម្លើងឋានៈ គ្រូនគរបាលជាតិកំរិតឧត្តម ថ្នាក់លេខ១ , ថ្នាក់លេខ២ , និង គ្រូនគរបាលជាតិ កំរិតមធ្យម ថ្នាក់លេខ១ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការតម្លើងឋានៈគ្រូនគរបាលជាតិ ក្រៅពីកំរិតនិងថ្នាក់ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា១១** : ឋានៈដូចមានចែងក្នុងមាត្រា៩ ខាងលើអនុវត្តសំរាប់តែមន្ត្រីនគរបាលជាតិ ជាគ្រូនគរបាលជាតិ ដែលស្ថិតនៅក្រៅមុខតំណែងដឹកនាំ ។

**មាត្រា១២**-: ការតម្លើងឋានន្តរសក្តិ គ្រូនគរបាលជាតិ ត្រូវអនុវត្តទៅតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

**មាត្រា១៣** : គ្រូនគរបាលជាតិ ត្រូវទទួលបានប្រាក់កម្រៃគរុកោសល្យ តាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា១៤** : គ្រូនគរបាលជាតិ ត្រូវមានកិច្ចសន្យាបំរើការងារជាគ្រូបង្រៀននគរបាលជាតិ រយៈពេលយ៉ាងតិច១០ឆ្នាំទើបមានសិទ្ធិសុំទៅបំរើការងារនៅតាមអង្គភាពផ្សេងៗទៀតបាន ។

**មាត្រា១៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១៦*
- *ឯកសារ-កាលប្បវត្តិ*